# ការណែនាំអំពីដូសជំរុញ

ព័ត៌មានតាមរយៈ CDC (មជ្ឈមណ្ឌលគ្រប់គ្រងជំងឺ) បានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី 27 ខែតុលា ឆ្នាំ 2021

Philly Counts

www.phila.gov/phillycounts

### តើដូសជំរុញមានរូបមន្តផ្សំដូចគ្នាទៅនឹងវ៉ាក់សាំងដែលមានស្រាប់ដែរឬទេ?

មាន។ ដូសជំរុញបង្ការជំងឺ COVID-19 មានរូបមន្តផ្សំដូចគ្នាទៅនឹងវ៉ាក់សាំង COVID-19 បច្ចុប្បន្ន។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងករណីចាក់វ៉ាក់សាំង Moderna COVID-19 ជាដូសជំរុញ វាគឺពាក់កណ្តាលដូសនៃវ៉ាក់សាំងដែលមនុស្សចាក់សម្រាប់វ៉ាក់សាំងស៊េរីដំបូងរបស់ពួកគេ។

### ប្រសិនបើយើងត្រូវការការចាក់ដូសជំរុញ តើវ៉ាក់សាំងមានប្រសិទ្ធភាពដែរឬទេ?

មាន។ វ៉ាក់សាំង COVID-19 មានប្រសិទ្ធភាពល្អ ដើម្បីបង្ការការពារជំងឺធ្ងន់ធ្ងរ ការដេកសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងការស្លាប់ ប្រឆាំងមេរោគបម្លែងខ្លួនថ្មីដែលតា ដែលកំពុងចរាចរយ៉ាងទូលំទូលាយ។ ទោះជាយ៉ាងណាក៏ដោយ អ្នកជំនាញផ្នែកសុខភាពសាធារណៈកំពុងចាប់ផ្តើមមើលឃើញការថយចុះសមត្ថភាពនៃប្រព័ន្ធការពារ ជាពិសេសក្នុងចំណោមប្រជាជនមួយចំនួន ប្រឆាំងនឹងជំងឺកម្រិតស្រាល និងជំងឺកម្រិតមធ្យម។

### តើមានហានិភ័យអ្វីខ្លះក្នុងការចាក់វ៉ាក់សាំងជំរុញ?

រហូតមកដល់ពេលនេះ ប្រតិកម្មដែលត្រូវបានរាយការណ៍បន្ទាប់ពីបានចាក់ដូសជំរុញគឺស្រដៀងទៅនឹងវ៉ាក់សាំងស៊េរី 2 ដូស ឬតែមួយដូស។ គ្រុនក្តៅ ឈឺក្បាល អស់កម្លាំង និងឈឺចាប់នៅកន្លែងចាក់គឺជាផលរំខានដែលត្រូវបានរាយការណ៍ជាទូទៅបំផុត ហើយជារួមផលរំខានភាគច្រើនគឺពីកម្រិតស្រាលទៅមធ្យម។ ទោះយ៉ាងណាក៏ដោយ ដូចជាមួយនឹងវ៉ាក់សាំងស៊េរី 2 ដូស ឬតែមួយដូស ផលប៉ះពាល់ធ្ងន់ធ្ងរគឺកម្រមានណាស់ ប៉ុន្តែអាចកើតឡើង។

### តើខ្ញុំនៅតែត្រូវបានចាត់ទុកថាបាន "ចាក់វ៉ាក់សាំងពេញលេញ" ដែរឬទេ បើខ្ញុំមិនបានចាក់ដូសជំរុញ?

មាន។ មនុស្សគ្រប់រូបនៅតែត្រូវបានចាត់ទុកថាបានចាក់វ៉ាក់សាំងពេញលេញពីរសប្តាហ៍បន្ទាប់ពីបានចាក់លើកទីពីរចំពោះក្នុងវ៉ាក់សាំងស៊េរី 2 ដូសដូចជា វ៉ាក់សាំង Pfizer-BioNTech ឬ Moderna ឬ ពីរសប្តាហ៍បន្ទាប់ពីបានចាក់វ៉ាក់សាំងប្រភេទតែមួយដូស ដូចជាវ៉ាក់សាំង &J/Janssen។

### តើនៅពេលណាដែលខ្ញុំអាចចាក់ដូសជំរុញបង្ការជំងឺ COVID-19 បាន ប្រសិនបើខ្ញុំមិននៅក្នុងក្រុមណាមួយដែលបានណែនាំ?

ចំនួនប្រជាជនបន្ថែមអាចត្រូវបានណែនាំឲ្យចាក់ដូសជំរុញនៅពេលដែលមានទិន្នន័យកាន់តែច្រើន។ វ៉ាក់សាំង COVID-19 ត្រូវបានអនុម័ត និងអនុញ្ញាតនៅក្នុងសហរដ្ឋអាមេរិក បន្តមានប្រសិទ្ធភាពក្នុងការកាត់បន្ថយហានិភ័យនៃជំងឺធ្ងន់ធ្ងរ ការដេកសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងការស្លាប់។ ក្រុមអ្នកជំនាញកំពុងមើលទិន្នន័យដែលមានទាំងអស់ ដើម្បីស្វែងយល់ពីរបៀបដែលវ៉ាក់សាំងធ្វើការបានល្អក្នុងកម្រិតណាសម្រាប់ប្រជាជនផ្សេងៗគ្នា។ នេះរួមបញ្ចូលទាំងការពិនិត្យមើលថាតើមេរោគបម្លែងខ្លួនថ្មីដូចជា ដែលតាប៉ះពាល់ដល់ប្រសិទ្ធភាពនៃវ៉ាក់សាំងយ៉ាងដូចម្តេច។

**ការសិក្សាជាច្រើនបង្ហាញថា បន្ទាប់ពីបានចាក់វ៉ាក់សាំងបង្ការជំងឺ COVID-19 ការការពារប្រឆាំងនឹងមេរោគនេះ និងសមត្ថភាពការពារការឆ្លងរោគបម្លែងខ្លួនថ្មីដែលតាអាចថយចុះទៅតាមពេលវេលា។**

ទោះបីជាការចាក់វ៉ាក់សាំង *COVID-19* សម្រាប់មនុស្សពេញវ័យដែលមានអាយុចាប់ពី *65* ឆ្នាំឡើងទៅនៅតែមានប្រសិទ្ធភាពក្នុងការការពារជំងឺធ្ងន់ធ្ងរក៏ដោយ ទិន្នន័យថ្មីៗបានបង្ហាញថា ការចាក់វ៉ាក់សាំងមិនសូវមានប្រសិទ្ធភាពក្នុងការការពារការឆ្លងមេរោគ ឬជំងឺស្រាលដែលមានរោគសញ្ញាទៅតាមពេលវេលានោះទេ។ ភស្តុតាងថ្មីៗក៏បង្ហាញថាក្នុងចំណោម បុគ្គលិកផ្នែកថែទាំសុខភាព និងបុគ្គលិកជួរមុខផ្សេងទៀត ប្រសិទ្ធភាពនៃវ៉ាក់សាំងប្រឆាំងនឹងការឆ្លងជំងឺ *COVID-19* ក៏ថយចុះទៅតាមពេលវេលាផងដែរ។ ប្រសិទ្ធភាពកម្រិតទាបនេះ ទំនងជាកើតឡើងដោយសារតែកត្តារួមបញ្ចូលគ្នានៃការថយចុះសមត្ថភាពនៃប្រព័ន្ធការការពារ នៅពេលដែលពេលវេលាកន្លងផុតទៅចាប់តាំងពីបានចាក់វ៉ាក់សាំង ក៏ដូចជាការឆ្លងកាន់តែខ្លាំងនៃមេរោគបម្លែងថ្មីដែលតា។ ទិន្នន័យពីការសាកល្បងគ្លីនិកតូចៗបង្ហាញថា ការចាក់ដូសជំរុញ *Pfizer-BioNTech* ឬ *Moderna* បានបង្កើនការឆ្លើយតបនៃប្រព័ន្ធភាពស៊ាំនៅក្នុងខ្លួន អ្នកចូលរួមការសាកល្បងព្យាបាលដែលបានបញ្ចប់ការចាក់វ៉ាក់សាំងស៊េរីដំបូងកាលពី *6* ខែមុន។ ការសាកល្បងព្យាបាលស្រដៀងគ្នានេះបានបង្ហាញថា ការចាក់ដូសជំរុញ *J&J/Janssen* ក៏បង្កើនការឆ្លើយតបនៃប្រព័ន្ធភាពស៊ាំចំពោះអ្នកចូលរួមដែលបានបញ្ចប់ការចាក់វ៉ាក់សាំងប្រភេទតែមួយដូសយ៉ាងហោចណាស់ *2* ខែមុន។ ជាមួយនឹងការកើនឡើងនៃការឆ្លើយតបនៃប្រព័ន្ធភាពស៊ាំ មនុស្សគួរតែមានការបង្កើនសមត្ថភាពការពារប្រឆាំងនឹងជំងឺ *COVID-19* កាន់តែល្អប្រសើរឡើង រួមទាំងមេរោគបម្លែងថ្មីដែលតាផងដែរ។

# BOOSTER FAQs

*Info via CDC (Centers for Disease Control), Updated Oct. 27, 2021;*

Philly Counts

*www.phila.gov/phillycounts*

## Are booster shots the same formulation as existing vaccines?

Yes. COVID-19 booster shots are the same formulation as the current COVID-19 vaccines. However, in the case of the Moderna COVID-19 vaccine booster shot, it is half the dose of the vaccine people get for their initial series.

## If we need a booster shot, are the vaccines working?

Yes. COVID-19 vaccines are working well to prevent severe illness, hospitalization, and death, even against the widely circulating Delta variant. However, public health experts are starting to see reduced protection, especially among certain populations, against mild and moderate disease.

## What are the risks of getting a booster shot?

So far, reactions reported after getting a booster shot were similar to that of the 2-shot or single-dose initial series. Fever, headache, fatigue and pain at the injection site were the most commonly reported side effects, and overall, most side effects were mild to moderate. However, as with the 2-shot or single-dose initial series, serious side effects are rare, but may occur.

## Am I still considered "fully vaccinated" if I don't get a booster shot?

Yes. Everyone is still considered fully vaccinated two weeks after their second dose in a 2-shot series, such as the Pfizer-BioNTech or Moderna vaccines, or two weeks after a single-dose vaccine, such as the J&J/Janssen vaccine.

## When can I get a COVID-19 booster shot if I am NOT in one of the recommended groups?

Additional populations may be recommended to receive a booster shot as more data become available. The COVID-19 vaccines approved and authorized in the United States continue to be effective at reducing risk of severe disease, hospitalization, and death. Experts are looking at all available data to understand how well the vaccines are working for different populations. This includes looking at how new variants, like Delta, affect vaccine effectiveness.

**Studies show after getting vaccinated against COVID-19, protection against the virus and the ability to prevent infection with the Delta variant may decrease over time.**

*Although COVID-19 vaccination for adults ages 65 years and older remains effective in preventing severe disease, recent data suggests vaccination is less effective at preventing infection or milder illness with symptoms over time. Emerging evidence also shows that among healthcare and other frontline workers, vaccine effectiveness against COVID-19 infections is also decreasing over time. This lower effectiveness is likely due to the combination of decreasing protection as time passes since getting vaccinated, as well as the greater infectiousness of the Delta variant. Data from small clinical trials show that a Pfizer-BioNTech or Moderna booster shot increased the immune response in trial participants who finished their initial series 6 months earlier. A similar clinical trial showed that a J&J/Janssen booster shot also increased the immune response in participants who completed their single-dose vaccine at least 2 months earlier. With an increased immune response, people should have improved protection against COVID-19, including the Delta variant.*